# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីការធ្វើបុណ្យចូលឆ្នាំខ្មែរ

**web site: hoksavann.org**

ថ្ងៃទី២៨ មីនា ២០០៥

បុណ្យចូលឆ្នាំខ្មែរតែងធ្វើនៅថ្ងៃ១៣មេសារៀងរាល់ឆ្នាំ តែយូរៗមានធ្វើនៅថ្ងៃ១៤មេសាម្តង ។ ពេលវេលានៃការកំណត់ចូលឆ្នាំនេះ គឺកំណត់ទៅតាមក្បួនហោរាសាស្ត្រ ដែលចេញផ្សាយជាផ្លូវការពីព្រះបរមរាជវាំងខ្មែរ ។ ទាក់ទងនឹងពេលវេលានៃការចូលឆ្នាំនេះ មានរឿងបុរាណមួយនិទានថា កបិលមហាព្រហ្មភ្នាល់ចាញ់ធម្មបាលកុមារជាមនុស្សលោក អំពីសេរីបីប្រការ គឺពេលព្រឹកយកទឹកលុបមុខ ពេលថ្ងៃត្រង់យកទឹកលាបទ្រូង និងពេលល្ងាចរៀបចូលដំណេក យកទឹកលាងជើង ។ នាងទេពធីតាទាំង៧នាក់ជាបុត្រីព្រហ្ម បានផ្លាស់វេនគ្នាក្នុង១ឆ្នាំម្តងរាល់១២ឆ្នាំ យកព្រះសិរគឺក្បាលព្រហ្មជាបិតាខ្លួន ពីភ្នំកៃលាសហែប្រទក្សិណភ្នំព្រះសុមេរុ ដោយមានព្រះទេពនិករជួយហែហមផង រួចហើយយកទៅដំកល់ទុកនៅភ្នំកៃលាសវិញ ។ នាងទេពធីតាជាអ្នកនាំផ្លូវដង្ហែក្បួននោះ មានអនុភាពសាយភាយ ចាប់តាំងពីថ្ងៃចូលឆ្នាំទៅអស់រយៈពេលមួយឆ្នាំគត់ ហើយមហាសង្ក្រាន្តក៏ចេញប្រកាសប្រាប់នូវគ្រោះកាចគ្រោះជាក្នុង១ឆ្នាំនោះ ។ សេចក្តីដំណាលនេះបានប្រកាសប្រាប់ថា ត្រូវឲ្យអស់មនុស្សផងទាំងឡាយ ខំធ្វើទានរក្សាសីលចំរើនមេត្តាភាវនាក្នុងឆ្នាំថ្មីនេះ នឹងបានសេចក្តីសុខក្សេមក្សាន្តអាយុយឺនយូរ ហើយទេវតានឹងជួយថែរក្សា ។

ពាក្យថា «សង្ក្រាន្ត ឬសង្ក្រាន្តិ» ប្រែថាដំណើរឃ្លាតចាកទី ការឈានចូលដល់ ដំណើរដែលព្រះអាទិត្យចរចូលដល់ទីជួបមួយជុំនៃរាសីចក្រ គឺដំណើរដែលដើមនិងចុងនៃរាសីចក្រជួបគ្នាពេញគ្រប់១ឆ្នាំ បានដល់ការដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មីនេះឯង ។ ដូច្នេះការកំណត់ចូលឆ្នាំខ្មែរនេះ គឺកំណត់តាមសុរិយគតិតាមដំណើរព្រះអាទិត្យ ។ មានន័យសេចក្តីថា ក្នុង១ឆ្នាំព្រះអាទិត្យធ្វើដំណើរបាន១ជុំ គឺឃ្លាតចាកពីចំណុច១ ហើយមកជួបចំណុចដដែលនោះវិញ ។ ស្របនឹងវិទ្យាសាស្ត្រថា ផែនដីបានវិលជុំវិញព្រះអាទិត្យបានមួយជុំក្នុង១ឆ្នាំ ។ ការចូលឆ្នាំនេះកំណត់៣ថ្ងៃ គឺថ្ងៃចូល ថ្ងៃកណ្តាល និងថ្ងៃឡើងស័ក ។

តាមប្រពៃណី មុនថ្ងៃចូលឆ្នាំ ជនជាតិខ្មែរបានរៀបចំប្រដាប់ប្រដាសំរាប់ធ្វើបុណ្យនិងសំរាប់ប្រើប្រាស់ និងទទួលទានទុកជាស្រេច ព្រោះក្នុងអំឡុងពេលបីថ្ងៃនេះ គេបញ្ឈប់ការងារទាំងអស់ សូម្បីអុសទឹកអង្ករ ក៏គេបំរុងទុកឲ្យហើយដែរ ។ ក្នុងឱកាសចូលឆ្នាំនោះ រដ្ឋបានឲ្យឈប់ធ្វើការ៣ថ្ងៃ ដូច្នេះទាំងអ្នករដ្ឋការ ទាំងប្រជាពលរដ្ឋ បានកាត់ទៅជួបជុំឪពុកម្តាយបងប្អូននៅភូមិកំណើតរៀងៗខ្លួន ដោយនាំយកទៅជាមួយខ្លួននូវវត្ថុសំរាប់ធ្វើបុណ្យនិងសំលៀកបំពាក់នំចំណី សំរាប់ប្រគេនព្រះសង្ឃនិងជូនឪពុកម្តាយខ្លួន ។ ពេលល្ងាចនៃថ្ងៃបុណ្យនេះ គេនាំគ្នាទៅវត្តស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តនិងទេសនា ពេលថ្ងៃគេរាប់បាត្រវេរចង្ហាន់ប្រគេនព្រះសង្ឃ បង្សុកូល ឧទ្ទិសកុសលដល់អ្នកដែលចែកស្ថានទៅ ។

ក្នុងថ្ងៃចូលឆ្នាំនោះ មានពិធីពូនភ្នំខ្សាច់ មានកន្លែងខ្លះយកស្រូវឬអង្ករពូនជំនួសខ្សាច់ ។ គេពូនធ្វើជាភ្នំធំមួយនៅចំកណ្តាល ឯភ្នំតូចៗបួនទៀតនៅសងខាង មានធ្វើរាជវ័តិព័ទ្ធជុំវិញ នៅជើងភ្នំមានដោតទង់ក្រដាសពណ៌ ទៀនធូបផ្កាភ្ញីផ្សេងៗ ។ មតិមួយយល់ថា ភ្នំធំកណ្តាល ជាតំណាងភ្នំព្រះសុមេរុ ជាស្នូលនៃពិភពលោក ឯភ្នំព័ទ្ធជុំវិញគ្រប់ទិស ជាតំណាងភ្នំសត្តបរិភណ្ឌ ដែលជាបរិវារភ្នំព្រះសុមេរុ ។ បើយើងធ្វើភ្នំ គ្រាន់តែមានន័យតំណាងភ្នំព្រះសុមេរុដូច្នេះ វាគ្មានខ្លឹមសារអ្វីសោះក្នុងការបង្កើតជាបុណ្យជាកុសល ដូច្នេះហើយបានជាមានមតិអ្នកប្រាជ្ញយល់ផ្សេងពីនេះថា ភ្នំធំនៅចំកណ្តាលជាតំណាងព្រះចូឡាមុនីចេតិយនៅស្ថានត្រៃត្រឹង្ស ដែលតំកល់ទុកនូវព្រះកេសា (សក់) នៃព្រះពុទ្ធសមណគោតមដែលទ្រង់បានកាត់ នៅពេលដែលព្រះអង្គទៅជាព្រះពោធិសត្វ ចេញសាងបព្វជាវិញទេ ។ មានមតិបន្ថែមទៀតថា ភ្នំធំកណ្តាលជាតំណាងព្រះសក្យមុនីចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុនៃព្រះអង្គ ឯភ្នំតូចបួនទៀតជាតំណាងចេតិយដែលបញ្ចុះអដ្ឋិធាតុរបស់ព្រះសារីបុត្ត ព្រះមោគ្គល្លានព្រះអានន្ទ និងព្រះមហាកស្សប ដែលជាសាវកដ៏សំខាន់របស់ព្រះអង្គ ។ យោបល់ខាងក្រោមនេះ ឃើញថាមានន័យល្អសំរាប់បង្កើតជាបុណ្យ ជាកុសល គឺយើងធ្វើភ្នំជានិមិត្តរូបនៃចេតិយដែលបញ្ចុះព្រះសារីរិកធាតុនៃព្រះពុទ្ធនិងសាវករបស់ព្រះអង្គ ដែលជាព្រះអរហន្តមានគុណធម៌ដ៏ខ្ពង់ខ្ពស់កំចាត់អំពើបាបអស់ហើយ ។ មួយទៀត ជំនឿរបស់មហាជនខ្មែរថាគ្រាប់ខ្សាច់មួយគ្រាប់ៗដែលចាក់ពូនភ្នំនោះ អាចផ្តល់អនិសង្សដល់អ្នកដែលពូន ឲ្យបានរួចរំដោះចាកបាបគ្រោះ ឬកម្មពៀរទៀតផង ។

ក្រៅពីពិធីពូនភ្នំខ្សាច់ មានពិធីស្រង់ព្រះ គឺគេយកទឹកទៅស្រោច ឬទៅរលាស់នៅលើព្រះពុទ្ធរូប ។ ពិធីនេះក៏ល្អ ព្រោះយើងធ្វើពិធីនេះដោយនឹកទៅដល់គុណធម៌ព្រះពុទ្ធមានព្រះនាមថាអរហំ ប្រែថាព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសជាដើម រមែងធ្វើចិត្តឲ្យជ្រះថ្លាស្ងប់ផ្លូវចិត្តមួយខណៈដែលជាហេតុនៃសេចក្តីសុខ ។ មិនត្រឹមតែស្រង់ព្រះពុទ្ធរូបទេ គឺកន្លែងខ្លះមានស្រង់ព្រះសង្ឃ រហូតងូតទឹកឲ្យមាតាបិតានិងចាស់ទុំ ដែលមានមានគុណធម៌មានសីលគុណទៀតផង ។

បុណ្យចូលឆ្នាំខ្មែរមានខ្លឹមសារពិសេសរបស់ខ្លួន គឺការពិចារណានូវដំណើរជីវិត ដែលប្រព្រឹត្តទៅក្នុងរយៈពេល១ឆ្នាំ ទុកជាមេរៀនសំរាប់ឆ្នាំថ្មី ក្នុងការរៀបចំផែនការជីវិតទៅមុខទៀត ឲ្យបានល្អជាងឆ្នាំចាស់ ។ លះអំពើអាក្រក់ក្នុងឆ្នាំចាស់សាងអំពើល្អក្នុងឆ្នាំថ្មី ។ នៅសម័យពុទ្ធកាល មានរឿងប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារ ដំណាលយ៉ាងសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិសារបាននិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកទទួលចង្ហាន់ ព្រះបាទពិម្ពិសារពុំបានតាំងចិត្តឧទ្ទិសកុសលដល់ពួកប្រេតដែលជាញាតិរបស់ព្រះអង្គ ពួកប្រេតទាំងនោះបានបន្លឺសម្លេងយំស្រែកជុំវិញព្រះរាជវាំង ជាសញ្ញាទាមទារបុណ្យកុសលដើម្បីឲ្យបានអាហារដើម្បីបរិភោគ ។ ដោយទូលសួរព្រះពុទ្ធជាម្ចាស់បានជ្រាបរឿងនេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ធ្វើបុណ្យជាលើកទី២ ហើយតាំងចិត្តឧទ្ទិសកុសលដល់ពួកប្រេតជាញាតិ ។ ចាប់ពីពេលនោះមក សម្លេងស្រែកក៏ស្ងាត់បាត់ទៅ ជាភស្តុតាងបញ្ជាក់ថា ពួកប្រេតជាញាតិបានទទួលផលបុណ្យនេះហើយ ។ រឿងនេះស្របនឹងរឿងក្នុងតិរោកុឌ្ឌសូត្រ ដែលចែងថា មានពួកប្រេតខ្លះអត់ឃ្លានរង់ចាំទទួលផលបុណ្យដែលញាតិមិត្តឧទ្ទិសឲ្យដល់ខ្លួន ។

យើងអាចសង្ខេបនូវអត្ថន័យនៃការធ្វើបុណ្យចូលឆ្នាំខ្មែរដូចតទៅនេះ ៖

★ ពិចារណាឲ្យកើតធម្មសង្វេគថា ពេលវេលាកន្លងទៅមួយឆ្នាំ អាយុរបស់យើងក៏អស់មួយឆ្នាំដែរ ដូច្នេះពុំគួរប្រមាទក្នុងជីវិតដែលចេះតែ

អស់ទៅសូន្យទៅនោះឡើយ ។

★ នាំឲ្យមានស្មារតីពិចារណាថា តើឆ្នាំចាស់កន្លងផុតទៅ ខ្លួនគេបានធ្វើអ្វីខ្លះ ? ដោយទុកឆ្នាំចាស់ជាមេរៀន រៀបចំផែនការជីវិតទៅមុខទៀតឲ្យល្អជាងឆ្នាំចាស់ ។

★ បើមានការទាស់ទែងខ្វែងគំនិតគ្នាក្នុងឆ្នាំចាស់កន្លងផុតទៅ លុះដល់ឆ្នាំថ្មីនេះ គេជានានឹងគ្នាវិញ ឈប់ប្រកួតប្រកាន់គ្នា ហើយស្រឡាញ់រាប់អានគ្នាដូចដើមវិញ ។

★ ក្រៅពីការបំពេញបុណ្យកុសលចំពោះព្រះសង្ឃ គេនាំគ្នាទិញសំលៀកបំពាក់ ម្ហូបចំណីជូនមាតាបិតាដែលជាអ្នកមានគុណ ។

★ គេផ្សាយបុណ្យផ្សាយកុសលជូនមាតាបិតាញាតិកាមិត្តសំឡាញ់ និងសព្វសត្វទាំងអស់ ដែលបានចែកស្ថានទៅហើយ ។

★ គេដាក់ទានដល់អ្នកក្រីក្រលំបាកតោកយ៉ាកកំព្រាអនាថាឥតទីពឹងដោយទឹកចិត្តអាណិតអាសូរ ។

★ សូម្បីសត្វតិរច្ឆាន មានគោក្របីជាដើមដែលតែងតែប្រើវា ក៏គេឈប់ប្រើវាក្នុងរវាងបីថ្ងៃ ហើយពោលសូមខមាទោសនឹងសត្វទាំងនោះទៀតផង កុំឲ្យមានកម្មមានពៀរទៅអនាគត នៅពេលខ្លួនប្រើធ្វើបាបវា ។

★ ពុំមែនសូមខមាទោសចំពោះតែសត្វដែលមានចិត្តមានវិញ្ញាណទេ សូម្បីធម្មជាតិដែលគ្មានចិត្តគ្មានវិញ្ញាណ ក៏បុព្វបុរសខ្មែរសម័យដើមសូមខមាទោសផងដែរ ដូចជាយកទឹកទៅច្រួចលើដី ហើយពោលសូនខមាទោសដីថា សូមកុំឲ្យខ្ញុំមានបាបមានកម្មមានពៀរ ព្រោះខ្ញុំបានបន្ទោរបង់មូត្រលាមកពីលើ ។

★ ក្រៅបីកម្មវិធីសាសនា គេមានលេខកំសាន្តដោយល្បែងផ្សេងៗ ដែលជាល្បែងឥតទោស ជាល្បែងហាត់ប្រាណ ជាល្បែងនាំឲ្យចិត្តរីករាយបង្កើតជាចំណងសាមគ្គីភាព ដូចជាល្បែងចោលឈូង ទាញព្រ័ត្រ ជាដើម ។៚